**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**
គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩
ក្នុងក្របខណ្ឌទូទាំងប្រទេស(គ.វ.ក-១៩)
លេខ......៦២៤/២១......គ.វ.ក-១៩

ថ្ងៃ ពុធ ៣ កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ,ថ្ងៃទី ១១ ខែសីហា ឆ្នាំ២០២១

# សេចក្តីជូនដំណឹងបន្ថែម
## ស្តីពី
## ការចាក់វ៉ាក់សាំងកូវីដ-១៩ (អាស្ត្រាហ្សេនីកា) ដូសជំរុញ ឬ ដូសទី៣

យោងតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស (គ.វ.ក-១៩) បានចេញសេចក្តីជូនដំណឹងលេខ ៥៦០/២១ គ.វ.ក-១៩ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២១ ស្តីពីការចាក់វ៉ាក់សាំងអាស្ត្រាហ្សេនីកា ដូសជំរុញ ឬ ដូសទី៣ ដល់គ្រូពេទ្យជួរមុខ និងមន្ត្រីរាជការ នៃខេត្តចំនួន៧ ដែលមានព្រំប្រទល់ជាប់ប្រទេសថៃ និងសេចក្តីជូនដំណឹងលេខ ៥៧៣/២១ គ.វ.ក-១៩ ស្តីពីការចាក់វ៉ាក់សាំងអាស្ត្រាហ្សេនីកា ដូសជំរុញ ឬ ដូសទី៣ នៅរាជធានីភ្នំពេញ។ ដើម្បីទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ឱ្យកាន់តែមានប្រសិទ្ធភាព និងដោយមានការយល់ព្រមដ៏ខ្ពង់ខ្ពស់ពី **សម្តេចតេជោនាយករដ្ឋមន្ត្រី** គ.វ.ក-១៩ នឹងពង្រីកការចាក់វ៉ាក់សាំងដូសជំរុញ ឬ ដូសទី៣ នេះជូនដល់មន្ត្រីរាជការថ្នាក់ជាតិ និងក្រោមជាតិ ដែលជាគោលដៅអាទិភាពជាបន្តបន្ទាប់ទៀត៖

**ក. ការចាក់វ៉ាក់សាំងអាស្ត្រាហ្សេនីកាដូសជំរុញ ឬដូសទី៣ ដល់មន្ត្រីរាជការស៊ីវិល និងនគរបាលថ្នាក់ជាតិ៖**

១. មន្ត្រីកាកបាទក្រហមកម្ពុជាថ្នាក់ជាតិ៖

ចំពោះមន្ត្រីកាកបាទក្រហមកម្ពុជាថ្នាក់ជាតិ ដែលបានចាក់វ៉ាក់សាំងស៊ីណូហ្វាម ឬស៊ីណូវ៉ាក់ ដូសទី១ និងដូសទី២ រួចរាល់ សូមអញ្ជើញទៅចាក់វ៉ាក់សាំងអាស្ត្រាហ្សេនីកាដូសជំរុញ ឬ ដូសទី៣ នៅមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក តាមកាលបរិច្ឆេទ និងពេលវេលាកំណត់ក្នុងតារាងខាងក្រោម៖

| ល.រ | ឈ្មោះក្រសួង និងស្ថាប័ន | កាលបរិច្ឆេទ | ពេលវេលា |
|---|---|---|---|
| ១ | -កាកបាទក្រហមកម្ពុជា | ១៨ ដល់ ២០ សីហា ឆ្នាំ២០២១ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |

២. កម្លាំងនគរបាលថ្នាក់ជាតិ៖

ចំពោះកម្លាំងនគរបាល ដែលកំពុងបម្រើការងារនៅថ្នាក់ជាតិ ហើយបានចាក់វ៉ាក់សាំងស៊ីណូហ្វាម ឬស៊ីណូវ៉ាក់ ដូសទី១ និងដូសទី២រួចរាល់ សូមអញ្ជើញទៅចាក់វ៉ាក់សាំងអាស្ត្រាហ្សេនីកាដូសជំរុញ ឬ ដូសទី៣ នៅមន្ទីរពេទ្យ ១៦ឧសភា តាមកាលបរិច្ឆេទ និងការរៀបចំចាត់ចែងរបស់អនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ក្នុងក្របខណ្ឌក្រសួងមហាផ្ទៃ។

**ខ. ការចាក់វ៉ាក់សាំងអាស្ត្រាហ្សេនីកា ដូសជំរុញ ឬដូសទី៣ ដល់មន្ត្រីរាជការថ្នាក់ក្រោមជាតិ នៃខេត្តចំនួន១៧៖**

ចំពោះមន្ត្រីរាជការថ្នាក់ក្រោមជាតិ មន្ត្រីជាប់កិច្ចសន្យា និងអាជ្ញាធរមូលដ្ឋាន (រួមទាំងបុគ្គលិកសុខាភិបាលឯកជន) ក្រោមឱវាទរដ្ឋបាលខេត្តចំនួន១៧ (ខេត្តកណ្តាល ព្រះសីហនុ កំពង់ស្ពឺ កំពង់ចាម កំពង់ឆ្នាំង កំពង់ធំ កំពត ក្រចេះ មណ្ឌលគិរី


ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរសព្ទ-ទូរសារ៖ (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

ព្រៃវែង រតនគិរី សៀមរាប ស្ទឹងត្រែង ស្វាយរៀង តាកែវ កែប និងខេត្តត្បូងឃ្មុំ) ដែលបានចាក់វ៉ាក់សាំងស៊ីណូហ្វាម ឬ ស៊ីណូវ៉ាក់ ដូសទី១ និងដូសទី២រួចរាល់ សូមអញ្ជើញទៅចាក់វ៉ាក់សាំងអាស្ត្រាហ្សេនីកាដូសជំរុញ ឬ ដូសទី៣ ដែលមានកាលបរិច្ឆេទ និងពេលវេលាកំណត់ នៅតាមទីតាំង ដែលនឹងត្រូវរៀបចំចាត់ចែងដោយរដ្ឋបាលខេត្តនីមួយៗខាងលើ។ ក្នុងន័យនេះ គ.វ.ក-១៩ តម្រូវឱ្យគ្រប់រដ្ឋបាលខេត្តខាងលើ ត្រូវរៀបចំចាត់ចែងការងារចាក់វ៉ាក់សាំងដូសជំរុញនេះឱ្យមានភាពរលូន និងត្រូវធ្វើសេចក្តីជូនដំណឹងដល់សាធារណជន អំពីកាលបរិច្ឆេទ ពេលវេលា និងទីតាំងចាក់វ៉ាក់សាំងដូសជំរុញ ឬ ដូសទី៣ តាមខេត្តរៀងខ្លួន។

**គ. ការចាក់វ៉ាក់សាំងអាស្ត្រាហ្សេនីកាដូសជំរុញ ឬដូសទី៣ ដល់អ្នកសារព័ត៌មានក្នុងរាជធានីភ្នំពេញ៖**

ចំពោះអ្នកសារព័ត៌មាន នៅរាជធានីភ្នំពេញ ដែលបានចាក់វ៉ាក់សាំងស៊ីណូហ្វាម ឬស៊ីណូវ៉ាក់ ដូសទី១ និងដូសទី២រួចរាល់ សូមអញ្ជើញទៅចាក់វ៉ាក់សាំងអាស្ត្រាហ្សេនីកាដូសជំរុញ ឬ ដូសទី៣ នៅមន្ទីរពេទ្យកុមារជាតិ តាមកាលបរិច្ឆេទ និងពេលវេលាកំណត់ក្នុងតារាងខាងក្រោម៖

| ល.រ | ឈ្មោះក្រសួង និងស្ថាប័ន | កាលបរិច្ឆេទ | ពេលវេលា |
|---|---|---|---|
| ១ | -អ្នកសារព័ត៌មានក្នុងរាជធានីភ្នំពេញ | ០៨ ដល់ ១៩ កញ្ញា ឆ្នាំ២០២១ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |

**ឃ. លក្ខខណ្ឌក្នុងការចាក់វ៉ាក់សាំងដូសជំរុញ ឬ ដូសទី៣៖**

អ្នកដែលអាចចាក់វ៉ាក់សាំងដូសជំរុញ ឬ ដូសទី៣ ដោយប្រើប្រាស់វ៉ាក់សាំងអាស្ត្រាហ្សេនីកាអំឡុងពេលនេះ ត្រូវគោរពទៅតាមលក្ខខណ្ឌដូចខាងក្រោម៖

- **អ្នកដែលបានចាក់វ៉ាក់សាំងស៊ីណូហ្វាម ឬ ស៊ីណូវ៉ាក់ រួចរាល់ទាំង២ដូស ហើយត្រូវមានគម្លាតពី៦ ទៅ ៨ខែ បន្ទាប់ពីដូសទី១**
- **ចំពោះអ្នកដែលបានចាក់វ៉ាក់សាំងអាស្ត្រាហ្សេនីកាទាំង២ដូសរួចហើយ សូមអនុវត្តតាមសារសម្លេងណែនាំដ៏ខ្ពង់ខ្ពស់របស់ សម្តេចតេជោនាយករដ្ឋមន្ត្រី នាល្ងាចថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២១ និងរង់ចាំការណែនាំនៅពេលក្រោយទៀត។**

**ង. ឯកសារត្រូវភ្ជាប់ជាមួយនៅពេលទៅចាក់វ៉ាក់សាំងដូសជំរុញ ឬ ដូសទី៣៖**

ចំពោះក្រុមគ្រូពេទ្យជួរមុខ មន្ត្រីរាជការ និងអាជ្ញាធរមូលដ្ឋាននានា ដែលបានចាក់វ៉ាក់សាំងស៊ីណូហ្វាម ឬ ស៊ីណូវ៉ាក់ ដូសទី១ និងដូសទី២រួចរាល់ ហើយត្រូវចាក់វ៉ាក់សាំងដូសជំរុញ ឬ ដូសទី៣ ត្រូវភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម៖

- ប័ណ្ណចាក់វ៉ាក់សាំងកូវីដ-១៩
- ប័ណ្ណសម្គាល់ខ្លួនមន្ត្រីរាជការ ឬ ប័ណ្ណសម្គាល់មន្ត្រីជាប់កិច្ចសន្យា
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ ឯកសារដែលប្រើប្រាស់ក្នុងការចុះឈ្មោះកាលពីចាក់វ៉ាក់សាំងដូសទី១

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ គ.វ.ក-១៩ សូមអំពាវនាវដល់ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាមន្ត្រីរាជការនៃកាកបាទក្រហមកម្ពុជាថ្នាក់ជាតិ នគរបាលថ្នាក់ជាតិ មន្ត្រីរាជការស៊ីវិលថ្នាក់ជាតិ និងមន្ត្រីរាជការ ព្រមទាំងអាជ្ញាធរមូលដ្ឋាន (រួមទាំងបុគ្គលិកសុខាភិបាលឯកជន) ក្រោមឱវាទរដ្ឋបាលខេត្តទាំងអស់ខាងលើ និងអ្នកសារព័ត៌មានក្នុងរាជធានី ភ្នំពេញ ដែលបានចាក់វ៉ាក់សាំងស៊ីណូហ្វាម ឬ ស៊ីណូវ៉ាក់ដូសទី១ និងដូសទី២រួចរាល់ ហើយដល់វេនអាចចាក់វ៉ាក់សាំងដូសជំរុញ ឬ ដូសទី៣ សូមអញ្ជើញទៅចាក់វ៉ាក់សាំងអាស្ត្រាហ្សេនីកាដូសជំរុញ ឬ ដូសទី៣ នេះឱ្យបានគ្រប់ៗគ្នានៅតាមទីតាំង និងកាលបរិច្ឆេទ នៃសេចក្តីជូនដំណឹងនេះ។ ទន្ទឹមគ្នានេះដែរ គ.វ.ក-១៩ សូមអំពាវនាវ ដល់មន្ត្រីរាជការ អាជ្ញាធរមូលដ្ឋាន រហូតដល់ប្រធានភូមិ និង អនុប្រធានភូមិ ព្រមទាំងបុគ្គលិកសេវាសុខាភិបាលឯកជនក្រោមឱវាទរដ្ឋបាលរាជធានី-ខេត្តទាំងអស់ សូមតាមដានសេចក្តីជូនដំណឹងរបស់រដ្ឋបាល រាជធានី-ខេត្តរបស់ខ្លួន អំពីកាលបរិច្ឆេទ ពេលវេលា និងទីតាំងចាក់វ៉ាក់សាំងអាស្ត្រាហ្សេនីកាដូសជំរុញនេះ និង សូមអញ្ជើញទៅចូលរួមចាក់វ៉ាក់សាំងដូសជំរុញនេះ នៅពេលដល់វេនរបស់ខ្លួន។

ប្រសិនបើបងប្អូនប្រជាពលរដ្ឋមានចម្ងល់ពាក់ព័ន្ធទៅនឹងការចាក់វ៉ាក់សាំងកូវីដ-១៩ (អាស្ត្រាហ្សេនីកា) ដូសជំរុញ ឬ ដូសទី៣ សូមទំនាក់ទំនងមកកាន់លេខទូរស័ព្ទខាងក្រោម៖

ក-ក្រុមការងារទំនាក់ទំនងសាធារណៈ /លេខាធិការដ្ឋាន៖

| | | |
|---|---|---|
| ០១២ ៩៨៩ ០៨៥ | ០៨៩ ៩៨០ ៦៦៦ | ០១២ ៧៧៧ ៧៦០ |

ខ-ក្រុមការងារចុះឈ្មោះ និងប្រព័ន្ធព័ត៌មានវិទ្យា៖

| | | |
|---|---|---|
| ០១២ ៨៩៧ ០៤៣ | ០៨៥ ៧៧៧ ០៥៦ | ០១២ ៨៦៨ ៦៤០ |

គ-ក្រុមការងារសុវត្ថិភាពវ៉ាក់សាំង និងប្រាស្រ័យទាក់ទងវ៉ាក់សាំង៖

| | | |
|---|---|---|
| ០១២ ៨៨៧ ៣៨៧ | ០១២ ៨៣៦ ៨៦៨ | ០១២ ៨៩១ ៥២៧ |

**រដ្ឋលេខាធិការ និងជាប្រធានគណៈកម្មការចំពោះកិច្ច**
**ចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស (គ.ច.ក-១៩)**

វេជ្ជ. ឱ្យ វណ្ណឌីន